# ស្វែងយល់ពីទស្សនវិជ្ជាអប់រំរបស់សាសនាព្រាហ្មណ៍
(Understanding of Educational Philosophy of Brahmanism)

*ដោយៈ ឯកឧត្តមបណ្ឌិត* ***អ៊ុំ ប៉ុម***
*ជំនួយការរាជបណ្ឌិត្យសភាកម្ពុជា*

## សេចក្តីផ្តើម

*សាសនាព្រាហ្មណ៍ឬព្រហ្មញ្ញសាសនា ឬហៅម្យ៉ាងទៀត ថាសាសនារបស់ព្រះព្រហ្ម ត្រូវបាននាំចូលមកប្រទេសឥណ្ឌាដោយពួកអារ្យ៉ន* (Aryan) *ដែលកាលនោះមានទីតាំងក្នុងភូមិភាគកូកាស* (caucase), *ប៉ាមៀ* (pamir) *និងឆ្នេរសមុទ្រអារ៉ាល់* (Aral)*។ នៅឆ្នាំ១៥០០ មុនគ.ស. ពួកអារ្យ៉នបានចូលមកលុកលុយប្រទេសក្នុងទ្វីបអឺរ៉ុបនិងភាគខាងជើងប្រទេសឥណ្ឌាហើយបានគ្រប់គ្រងលើពួកដ្រាវីឌីយាង* (Dravidien) *ដែលជាម្ចាស់ស្រុកនៃទឹកដីឥណ្ឌា។ ពួកព្រាហ្មណ៍ដែលបានចាត់ទុកខ្លួនគេថាជាបុត្ររបស់ព្រះព្រហ្មគឺជាអ្នកថែរក្សា និងផ្សព្វផ្សាយសាសនាព្រាហ្មណ៍របស់ពួកអារ្យ៉ន។ គេអាចចែកសាសនាព្រាហ្មណ៍ជាបីសម័យកាលធំៗរួមមានៈ*

*-សម័យវេទនិយមពីឆ្នាំ១៥០០មុនគ.ស. ដល់ ៥៥០មុនគ.ស.*

*-សម័យព្រាហ្មណ៍និយមពីឆ្នាំ៥៥០មុន គ.ស. ដល់សតវត្សរ៍ទី១០ នៃគ.ស. និង*

*-សម័យហិណ្ឌូនិយមពីសតវត្សរ៍ទី១០ នៃគ.ស. រហូតដល់បច្ចុប្បន្ន។*

*ខាងក្រោមនេះគឺជាទស្សនៈអប់រំដ៏សំខាន់ៗរបស់សាសនាព្រាហ្មណ៍ដែលអ្នករៀបរៀងអត្ថបទបានរកឃើញ។*

### ***១-ទស្សនៈអប់រំស្តីពីអាទិទេព***

*ពួកព្រាហ្មណ៍មានទស្សនៈថា ពិភពលោកយើងនេះត្រូវបានបង្កើតឡើងដោយទេវៈ ឬអាទិទេព។ មនុស្សនៅលើផែនដីយើងនេះ និងភាវៈដទៃទៀតក៏ត្រូវបានបង្កើតឡើងដោយអាទិទេពដូចគ្នាដែរ។*

*ដូច្នេះមនុស្សចាំបាច់ត្រូវគោរពចំពោះអាទិទេព។ អាទិទេពសំខាន់ៗក្នុងសាសនា*

ព្រាហ្មណ៍មានបីអង្គគឺព្រះព្រហ្ម ព្រះវិស្ណុ ឬព្រះនារាយណ៍ និងព្រះសិវៈឬព្រះឥសូរ។

## ១.១.ព្រះព្រហ្ម

ព្រះព្រហ្មជាទេវៈមួយអង្គក្នុងចំណោមទេវៈទាំងបីរបស់សាសនាព្រាហ្មណ៍ ហើយមានតួនាទីសំខាន់ ជាងអាទិទេពដទៃទៀត។ ព្រះព្រហ្មជាអ្នកបង្កើតលោកឋានសំខាន់ទាំងពីរគឺ ឋានទេវលោក (នៅលើមេឃ) និងឋានមនុស្សលោក (នៅលើផែនដី)។ ដោយឡែកនៅឋានមនុស្សលោក ព្រះព្រហ្មបានបង្កើតទឹកនិងភ្លើង បន្ទាប់មកព្រះព្រហ្មបានបង្កើតឱ្យមានជាជ្រោះ ជ្រលងជងអូរ ទន្លេសមុទ្រ ព្រមទាំងភាវៈមានជីវិតដទៃទៀត ដូចជារុក្ខជាតិមនុស្សនិងសត្វនានា។ កាលដើមឡើយព្រះព្រហ្មជាអាទិទេពគ្មានរូបកាយគ្មានប្រពន្ធកូនដូចមនុស្សលោកឡើយ។ ប៉ុន្តែក្រោយមកដើម្បីឱ្យរឹតតែមានជំនឿនិងស្របទៅតាមកាលៈទេសៈក៏ដូចជាតម្រូវការរបស់ប្រជាជនពួកព្រាហ្មណ៍ បានកែប្រែទស្សនៈដើមដោយធ្វើឱ្យព្រះព្រហ្មមានរូបរាងពិតប្រាកដមានប្រពន្ធកូនដូចមនុស្សលោកយើងនេះដែរព្រមទាំងមានព្រះភក្ត្រ (មុខបួន) អាចក្រឡេកមើលទៅទិសទាំងបួនក្នុងពេលជាមួយគ្នាបាន។

## ១.២.ព្រះវិស្ណុឬព្រះនារាយណ៍

ព្រះវិស្ណុឬព្រះនារាយណ៍ជាអាទិទេពទី២ ក្នុងសាសនាព្រាហ្មណ៍មានតួនាទីជាអ្នកគ្រប់គ្រងនិងថែរក្សាលោក (conservator God)។ ដើម្បីបំពេញនូវតួនាទីទាំងពីរនេះព្រះវិស្ណុតែងតែបែងភាគជាអវតារចុះមកឋានមនុស្សលោកហើយបំផ្លាញសភាវៈអាក្រក់ដែលបៀតបៀនបំផ្លិចបំផ្លាញសេចក្តីសុខនិងរបៀបរៀបរយរបស់ពិភពលោកដែលព្រះព្រហ្មបានខិតខំបង្កើតឡើង។

## ១.៣.ព្រះសិវៈឬព្រះឥសូរ

ព្រះសិវៈឬព្រះឥសូរជាអាទិទេពមានតួនាទីបង្កើតលោកផងនិងបំផ្លាញលោកផង (creator and destructor God)។ ព្រះសិវៈជាតំណាងកម្លាំងបំផ្លិចបំផ្លាញឱ្យអន្តរាយទៅវិញដូចជាមរណភាពនិងការផ្តាច់អាត្មានពីរូបកាយចាស់ដែលត្រូវវិនាសទៅដើម្បីបង្កើតនូវរូបកាយថ្មីទៀតដែលជាភាវៈមានជីវិត។ គេសាងរូបព្រះសិវៈឬព្រះឥសូរដោយសិវលិង្គឬ

លិង្គព្រះឥសូរ[1] ក្រៅពីនេះគេឃើញមានសាងរូបព្រះសិវៈឬព្រះឥសូរជាសិវលិង្គដាក់តម្កល់លើយោនីនាងឧមាដែលជានិមិត្តរូបនៃការបង្កើតលោករបស់ព្រះសីវៈ។

ក្រៅពីអាទិទេពទាំងបីអង្គ គេឃើញមានអាទិទេពបន្ទាប់បន្សំជាច្រើនទៀតដូចជាព្រះឥន្ទ្រជាទេវៈបង្កើតផ្គររន្ទះ។

ព្រះអគ្គីឬព្រះអគ្និជាទេវៈបង្កើតភ្លើងដែលជានិមិត្តរូបនៃអំពើល្អឬភាពស្មោះត្រង់របស់មនុស្ស។

ព្រះសូរ្យជាទេវៈបង្កើតកម្ដៅនិងពន្លឺជាថៅក្រមកាត់ក្ដីឱ្យមនុស្សលោក។ ព្រះចន្ទឬព្រះសោមៈជាទេវៈតំណាងសោភ័ណភាព ព្រោះព្រះចន្ទមានរូបឆោមលោមពណ៌ល្អ ហើយជាអ្នកថែរក្សារុក្ខជាតិនៅលើផែនដី។

ព្រះយមៈជាទេវៈតំណាងសេចក្ដីស្លាប់ ជាអ្នកធ្វើទោសមនុស្សដែលស្លាប់ទៅហើយ ដែលបានប្រព្រឹត្តអំពើអាក្រក់កាលពីពេលនៅរស់។ ព្រះវាយុជាទេវៈបង្កើតខ្យល់ជាទេវៈតំណាងកម្លាំងនិងល្បឿន។

[1] ១-លិង្គព្រះឥសូរដើមឡើយជាតំណាងសសរភ្លើងកើតឡើងដោយឯកឯង។

## ២ ទស្សនៈស្ដីពីការគ្រប់គ្រងរដ្ឋនិងសង្គម

### ២.១ ទស្សនៈស្ដីពីវណ្ណៈ

សាសនាព្រាហ្មណ៍បានដើរតួនាទីយ៉ាងសំខាន់ក្នុងការរួមចំណែករៀបចំសណ្ដាប់ធ្នាប់សង្គម ដឹកនាំសង្គមដោះស្រាយទំនាស់ក្នុងសង្គម។ ជាក់ស្ដែងដើម្បីគ្រប់គ្រងឱ្យមានប្រសិទ្ធភាព ពួកព្រាហ្មណ៍បានបែងចែកមនុស្សក្នុងសង្គមជាវណ្ណៈបួនប្រភេទ វណ្ណៈព្រាហ្មណ៍ វណ្ណៈក្សត្រ វណ្ណៈវេស្ស វណ្ណៈសូទ្រៈ។ ក្នុងចំណោមវណ្ណៈទាំងបួនវណ្ណៈសូទ្រៈជាវណ្ណៈទាបជាងគេបំផុត។ ជាវណ្ណៈបម្រើវណ្ណៈដទៃអស់មួយជីវិតនិងតកូនតចៅ។ ដោយឡែក ចំពោះកិច្ចការដឹកនាំរដ្ឋវិញត្រូវស្ថិតក្រោមវណ្ណៈព្រាហ្មណ៍និងវណ្ណៈក្សត្រ ដែលជាវណ្ណៈខ្ពស់បំផុតអាចទាក់ទងផ្ទាល់ជាមួយអាទិទេពនិងជាតំណាងអាទិទេព។ គួរកត់សម្គាល់ថាមនុស្សស្ថិតក្នុងវណ្ណៈនីមួយៗ មិនអាចផ្លាស់ប្ដូរវណ្ណៈរបស់ខ្លួនបានឡើយ លើកលែងតែបុគ្គលនោះស្លាប់ទៅហើយបាន

ប្រព្រឹត្តអំពើល្អកាលពីពេលនៅរស់។ ដោយសារតែអាទិទេពមានតួនាទីបង្កើតលោក ពួកព្រាហ្មណ៍បានផ្តល់ឱ្យអាទិទេពនូវអំណាចមួយក្នុងការកំណត់ជោគវាសនារបស់មនុស្សម្នាក់ៗ ពោលគឺមនុស្សម្នាក់ៗមិនអាចតវ៉ា រើបម្រាស់ខ្លួនពីវណ្ណៈដើមឬធ្វើអ្វីឱ្យហួសពីការកំណត់របស់អាទិទេពបានឡើយ។ ជំនឿបែបនេះបានជះឥទ្ធិពលគ្របដណ្តប់ទៅលើនយោបាយដឹកនាំនិងគ្រប់គ្រងសង្គម ពោលគឺធ្វើឱ្យការដឹកនាំនិងគ្រប់គ្រងសង្គមប្រព្រឹត្តទៅដោយរលូននិងគ្មានឧបសគ្គឬការប្រឆាំងជំទាស់អ្វីឡើយ។

### ២.២.ច្បាប់មនុ (Manu's law)

"ច្បាប់មនុ" ជាច្បាប់ពួកព្រាហ្មណ៍បង្កើតឡើងដើម្បីធ្វើឱ្យរដ្ឋមួយអាចដំណើរការទៅបាន។ ចំពោះមនុវិញគឺជានាមរបស់ព្រះព្រហ្មដែលជាអាទិទេពបង្កើតលោកនិងភាវៈទាំងឡាយក្នុងលោក។តាមទស្សនៈរបស់ពួកព្រាហ្មណ៍មនុជានាមរបស់បុរសជាបិតាដើមរបស់មនុស្សលោកស្ថិតក្នុងបឋមកប្បដែលជាពេលវេលាយូរអង្វែង ដើមដំបូងនៃអាយុកាលផែនដី។

ម្យ៉ាងទៀតដើម្បីដឹកនាំនិងគ្រប់គ្រងរដ្ឋមួយឱ្យបានល្អ រដ្ឋនោះត្រូវមានជាបឋមនូវអំណាច។ អំណាចនេះជាអំណាចដឹកនាំនិងគ្រប់គ្រងរដ្ឋឬរាជាណាចក្ររបស់ព្រះមហាក្សត្រតែមួយអង្គឯង (One king rule) ប៉ុណ្ណោះ។

ទន្ទឹមនឹងនេះក្នុងការដឹកនាំនិងគ្រប់គ្រងអាណាចក្រ ព្រះមហាក្សត្រត្រូវស្តាប់ឱវាទនិងការណែនាំរបស់សាមណព្រាហ្មណ៍ដែលជាអ្នកបួសនិងជាព្រះរាជគ្រូវិស័យដូចជាសិស្សគណត្រូវស្តាប់បង្គាប់គ្រូអាចារ្យ ក៏ដូចជាស្តាប់បង្គាប់ឪពុកម្តាយដូច្នេះដែរ។ ប្រការដែលសំខាន់ជាងនេះទៅទៀតរដ្ឋត្រូវដំណើរការក្រោមធាតុទាំងប្រាំពីរ (Seven Elements) ពោលគឺត្រូវមានព្រះមហាក្សត្រដែលតំណាងឱ្យអំណាចដឹកនាំនិងគ្រប់គ្រងរដ្ឋដូចបានបញ្ជាក់រួចមកហើយ បន្ទាប់មកត្រូវមានទីប្រឹក្សាដែលជាអ្នកផ្តល់យោបល់ចំពោះកិច្ចការធំៗ ជាអាយុជីវិតរបស់ជាតិ។ បន្ទាប់មកទៀតរដ្ឋត្រូវមានទីតាំងឈរជើងតំណាងបូរណភាពទឹកដីទាំងមូល។ ទន្ទឹមនឹងនេះរដ្ឋត្រូវមានធនធានរួមទាំងធនធានមនុស្សធនធានក្រោមដីលើដី...។ រដ្ឋត្រូវមាន"មាស"

ដែលជារូបិយវត្ថុដ៏សំខាន់ទ្រទ្រង់ខឿនពាណិជ្ជកម្មរបស់ប្រទេសត្រូវមានទាហានឬកងទ័ពខ្លាំងក្លាសម្រាប់ការពារខឿនឯករាជ្យអធិបតេយ្យនិងបូរណភាពដែនដី ហើយជាចុងក្រោយរដ្ឋត្រូវមានជាចាំបាច់នូវសម្ព័ន្ធមិត្តអន្តរជាតិធ្វើជាទីបង្អែកដ៏រឹងមាំនិងជួយឧបត្ថម្ភរដ្ឋនោះពីខាងក្រៅ។

## ៣ ទស្សនៈស្តីពីលទ្ធិ

ដូចបានបញ្ជាក់ពីខាងដើមរួចខ្លះមកហើយ ទន្ទឹមនឹងការបង្កើតអាទិទេព ព្រះព្រហ្មដែលជាអាទិទេពសំខាន់ទី១ពួកព្រាហ្មណ៍នូវបានបង្កើតឱ្យមានជាលទ្ធិចំនួនបួននៅអមជាមួយព្រះព្រហ្ម រួមមានលទ្ធិព្រហ្មចារ្យឬលទ្ធិព្រហ្មចារីយ៍ លទ្ធិអាត្ម័ន លទ្ធិឧបនិស័ទ និងលទ្ធិកម៌នសម្រាប់ធ្វើជាមូលដ្ឋានទ្រទង់ជំនឿប្រជាជនឥណ្ឌាចំពោះសាសនាព្រាហ្មណ៍ឱ្យកាន់តែមុតមាំថែមទៀត។

### ៣.១ លទ្ធិព្រហ្មចារ្យ (ព្រហ្មចារីយ៍)

ជាលទ្ធិសម្រាប់ប្រព្រឹត្តនិងធ្វើចិត្តឱ្យបានល្អដូចព្រះព្រហ្មទើបអាចតំណាងព្រះព្រហ្មបាន ហើយដើម្បីសម្រេចនូវគោលបំណងដ៏ល្អនេះបានពួកសាវ័កដើរតាមសាសនាព្រាហ្មណ៍ត្រូវហ៊ានលះបង់ប្រពន្ធកូនទ្រព្យសម្បត្តិនិងអ្វីៗទាំងអស់ទៅបួសជាសាមណព្រាហ្មណ៍ក្នុងព្រៃស្មសានឋានស្ងាត់។

### ៣.២ លទ្ធិអាត្ម័ន

ពាក្យអាត្ម័ន (Soul) មានឫសគល់មកពីពាក្យសំស្ក្រឹត "អាត្ម័ន" ត្រូវនឹងពាក្យបាលី អត្ត ឬ អាត្មា ប្រែជាខ្មែរថាខ្លួន ចិត្តឬព្រលឹងក៏បាន។ ពួកព្រាហ្មណ៍ចាត់ទុកអាត្ម័ន (ព្រលឹង) ជាធាតុពិសេសមួយ (Special Element) ដែលនៅជាប់នឹងព្រហ្ម័នជាឯកធាតុ។ អាត្ម័នអាចបែកចេញពីព្រហ្ម័នទៅកើតជាភាវៈផ្សេងទៀត (ភាវៈជាសត្វឬភាវៈជាមនុស្ស) ហើយជាចុងក្រោយ ត្រឡប់មកជួបនឹងព្រហ្ម័នវិញនៅពេលដែលអាត្ម័នអស់កម៌នមានន័យថា អស់កម្ម លែងវិលវល់ ក្នុងការកើតស្លាប់តទៅទៀត ហើយស្ថិតក្នុងបរមសុខឬមោក្សៈ[2]ជារៀងរហូត។ ម្យ៉ាងទៀតលទ្ធិអាត្ម័នជាលទ្ធិសម្រាប់អប់រំមនុស្សឱ្យចេះសម្អិតសម្អាងអាត្ម័នរបស់ខ្លួនឱ្យបានស្អាតផូរផង់ប្រាសចាកនូវអំពើ

២ -បើតាមព្រះពុទ្ធសាសនាថានិព្វាន។

អាក្រក់ដែលជាគ្រឿងមន្ទិលសៅហ្មង ទាំងឡាយដើម្បីធាប់បានវិលត្រឡប់ទៅជួប នឹងព្រហ្មันវិញ។ ដោយសារតែលទ្ធិអាត្មันនេះ បានធ្វើឱ្យមនុស្សខិតខំដោយខ្លួនឯងប្រព្រឹត្ត អំពើល្អដ៏មានប្រយោជន៍ចំពោះសង្គម ចៀស វាងអំពើអាក្រក់ពីព្រោះអំពើដែលខ្លួនប្រព្រឹត្ត ជាតំណាងអំពើរបស់ព្រះព្រហ្មដែលជាអំពើ ស្អាតបរិសុទ្ធបំផុត។

### ៣.៣ លទ្ធិឧបនិស័ទ

គោលសំខាន់របស់លទ្ធិឧបនិស័ទគឺ ការស្វែងរកវិធីធ្វើឱ្យអាត្មันឬព្រលឹងរបស់ មនុស្សធាប់បានវិលត្រឡប់ទៅជួបព្រហ្មន វិញ។ មានវិធីពីរយ៉ាងដែលធ្វើឱ្យអាត្មันធាប់ បានវិលត្រឡប់ទៅជួបអាត្មันវិញគឺវិធីតបៈនិង យោគៈ។

- តប : មានន័យបីយ៉ាង៖

- នៅដើមសម័យវេទតបៈមានន័យថា ព្យាយាមបន់ស្រន់ឱ្យអាទិទេពអាណិតអាសូរ ហើយពេញចិត្តនឹងជួយឱ្យសម្រេចអ្វីៗគ្រប់យ៉ាង ទៅតាមបំណងប្រាថ្នា។

- នៅចុងសម័យវេទ តបៈមានន័យថាធ្វើ ឱ្យអាទិទេពក្តៅអន្ទះអន្ទែងទ្រាំពុំបានត្រូវតែចុះ មកជួយមនុស្សលោក។

- នៅសម័យព្រាហ្មណ៍និយម តបៈ មានន័យថា ធ្វើឱ្យខ្លួនក្តៅក្រហាយលំបាក វេទនាដោយប្រការផ្សេងៗ ដូចជាអង្គុយ កណ្តាលថ្ងៃក្តៅ ដេកលើបន្លាឬដែកគោល ស្រួចៗឬធ្ងន់ធ្ងរជាងនេះទៅទៀតគឺអត់អាហារ ជាដើម។

- **យោគ** : ដោយមើលឃើញវិធី នេះ ពុំសូវមានប្រសិទ្ធភាព ពិបាកនឹងប្រព្រឹត្ត ផងនោះ ពួកព្រាហ្មណ៍បានបង្កើតឱ្យមានវិធី មួយផ្សេងទៀតគឺវិធីយោគ : (Yoga Method)។ យោគៈជាវិធីអប់រំចិត្តឱ្យនឹងនស្អាតបរិសុទ្ធដឹង ខុសត្រូវល្អអាក្រក់ ដោយផ្តើមចេញពីវិធីធ្វើលំ ហាត់ដកដង្ហើមចេញចូលឱ្យបានស្រួលឬហៅ ម៉្យាងទៀតថាវិធីធ្វើ "សមាធិ"[3]។

### ៣.៤ លទ្ធិកម៌ន(Karma doctrine)

"កម៌ន" ជាពាក្យសំស្ក្រឹតត្រូវនឹងពាក្យ បាលីថាកម្មត្រូវនឹងពាក្យខ្មែរថា "អំពើ" រួមទាំង អំពើល្អឬអាក្រក់តាមផ្លូវកាយវាចានិងផ្លូវចិត្ត។

---

៣-សមាធិក្នុងព្រះពុទ្ធសាសនាក៏មានដែរ។

ក្នុងសាសនាព្រាហ្មណ៍[4] ពាក្យកម៌ន មានន័យបីយ៉ាង ៖

***ន័យទីមួយ** កម៌នជាបុព្វហេតុនាំឱ្យ មានការកើត ស្លាប់ដែលជាសកម្មភាពប្រព្រឹត្ត ទៅបន្តបន្ទាប់គ្នាហើយជាសកម្មភាពទៀង ទាត់សម្រាប់ភាវៈរស់ទាំងអស់។*

***ន័យទីពីរ** កម៌នជាទំនាក់ទំនងរវាង អំពើនិងផល។ ផលចេញមកពីអំពើដែលបាន សាងហើយមិនចេះសាបសូន្យឡើយ។ កម៌ន ធ្វើឱ្យមនុស្សឬសត្វដែលជាភាវៈមានចលនា ហើយត្រូវវិនាសឬស្លាប់ទៅវិញនៅទីបំផុត។ ពេលស្លាប់ទៅរូបកាយត្រូវបាត់បង់មែនប៉ុន្តែ អាត្ម័នឬព្រលឹងមិនស្លាប់ឡើយ។ អាត្ម័នចេញ ពីរូបកាយដែលស្លាប់ទៅរករូបកាយថ្មីមួយ ទៀតតាមកម្រិតនៃអំពើឬកម្ម (កម៌ន) ដែល បានប្រព្រឹត្តកាលពីពេលនៅរស់។*

***ន័យទីបី** កម៌នសម្គាល់ការផ្តល់ផល ជារង្វាន់ឬក៏ជាទោសទណ្ឌកំណត់ដោយអាទិ ទេពហើយដែលបុគ្គលមិនអាចហាមឃាត់ឬ ប្រកែកប្រណាំងពុំព្រមទទួលយកនោះបាន ឡើយ វិស័យដូចជាព្រេងវាសនារបស់មនុស្ស ម្នាក់ៗនោះឯង។ សង្ខេបមកលទ្ធិព្រហ្ម័ន អាត្ម័ន និងកម៌នជាទ្រឹស្តីដ៏សំខាន់បីក្នុងចំណោមទ្រឹស្តី ទាំងបួនរបស់សាសនាព្រាហ្មណ៍ ហើយលទ្ធិ ទាំងបីនេះជាចំណងចង់ភ្ជាប់មនុស្សទៅនឹង ជំនឿយ៉ាងមុតមាំចំពោះអាទិទេព។*

## សេចក្តីសន្និដ្ឋាន

*រួមសេចក្តីមកសាសនាព្រាហ្មណ៍ជា សាសនាមួយដែលត្រូវបាននាំចូលមកប្រទេស ឥណ្ឌាដោយពួកអារ្យ៉ែន តាំងពីឆ្នាំ១៥០០មុន គ.ស. ហើយសាសនានេះមានការវិវត្តនិងរីក ចម្រើនទៅតាមដំណាក់កាលនីមួយៗរហូត មកដល់ពេលបច្ចុប្បន្នក្រោមរូបភាពជា សាសនាហិណ្ឌូព្រមជាមួយនេះសាសនា ព្រាហ្មណ៍ក៏មានបង្កប់ទៅដោយទស្សនៈអប់រំ មួយចំនួនដូចបានរៀបរាប់រួចមកហើយ ក្នុង គោលលទ្ធិទាំងបួនរបស់សាសនានេះទាក់ទង ទៅនឹងហេតុផលនៃការកើតស្លាប់របស់មនុស្ស វិធីអប់រំតាមផ្លូវកាយវាចាចិត្តឱ្យស្អាតបរិសុទ្ធ ដូចព្រះព្រហ្មព្រមទាំងគោលទ្រឹស្តីមួយចំនួន ទៀតដែលមានសារប្រយោជន៍ចំពោះការ*

៤-ព្រេងវាសនាតាមសាសនាព្រាហ្មណ៍ គឺជាការ កំណត់របស់អាទិទេពដែលមនុស្សត្រូវទទួលយក។

គ្រប់គ្រងរដ្ឋនិងសង្គមក៏ដូចជាធ្វើឱ្យរដ្ឋមួយមានដំណើរប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាពហើយទាំងអស់នេះគឺជាចំណងទាក់ទងយ៉ាងជិតស្និទ្ធរវាងសាសនានិងការប្រព្រឹត្តដើម្បីញ៉ាំងឱ្យមនុស្សជាសាវ័កកាន់តែមានជំនឿជឿជាក់យ៉ាងមុតមាំទៅលើតួនាទីកំណត់សម្រេចដោគវាសនារបស់មនុស្សពីសំណាក់អាទិទេព។




គំនូសបំព្រួញស្តីពីលទ្ធិព្រហ្ម័នក្នុងសាសនាព្រាហ្មណ៍

## គន្ថនិទ្ទេស


១ សុខ គាង វិទ្យាសាស្រ្តនយោបាយ ភ្នំពេញ ឆ្នាំ២០០៥

២ សែម សូរ វប្បធម៌ខ្មែរឥណ្ឌា ភ្នំពេញ ឆ្នាំ១៩៧១

៣ សោម ង៉ន ពន្លឺពុទ្ធសាសនា បោះពុម្ពលើកទី៣ ភ្នំពេញ ឆ្នាំ២០០៥។